**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ៦៨៦/៣០-៧-២០១៣
**សាលដីកា**
លេខ០៨ក្រVIឃ
ចុះថ្ងៃទី០៨-០១-២០១៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី២៤-១២-២០១៣ដែលមានសមាសភាពដូចតទៅ៖

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជំរះ</u>**

**លោក [redacted] ប្រធាន**

**លោក [redacted] ចៅក្រមប្រឹក្សា**

**លោក [redacted] ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក [redacted]**

**ក្រឡាបញ្ជី**

**លោកស្រី [redacted]**

ជំនុំជំរះលើបណ្តឹងស្រូបទោសនៃសំណុំរឿងព្រហ្មទណ្ឌលេខ៦៨៦/៣០-៧-២០១៣របស់សាលាឧទ្ធរណ៍៖

**-ជនជាប់ចោទឈ្មោះ [redacted] សុខលីន(ដើមបណ្តឹងឧទ្ធរណ៍)**ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរកម្មកររោងចក្រ កើតនៅ និង ទីលំនៅសព្វ [redacted] ជំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រ)ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន១នាក់ ។ទោសពីមុន គ្មាន។ចាប់ខ្លួនថ្ងៃទី២៥-១០-២០០៨។**មានមេធាវី អ៊ឹម ម៉ាច.**

**<u>ដំណើររឿងមានដូចតទៅ៖</u>**

តាមបណ្តឹងសុំស្រូបទោសបញ្ចូលគ្នាចុះថ្ងៃទី១៥-៧-២០១៣របស់ឈ្មោះ [redacted] សុខ

លើន បញ្ជាក់ថា ខ្លួនត្រូវបានសាលាដំបូងខេត្តកណ្តាល និង សាលាឧទ្ធរណ៍សំរេចផ្តន្ទាទោសលើសំណុំរឿងចំនួន០២រឿងគឺៈ

១-សាលដីកាព្រហ្មទណ្ឌលេខ០៦ក្រ៥.ប/១៧-០២-២០១១ សំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន០២ឆ្នាំ៦ខែ ពីបទបើកបរបង្កឲ្យស្លាប់អ្នកដទៃ ។

២-សាលដីកាព្រហ្មទណ្ឌលេខ៩៣ក្រIIIយេ/២៥-១០-២០១១ សំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន០៥ឆ្នាំ ពីបទរំលោភសេពសន្ថវៈ ។

បច្ចុប្បន្នសាលដីកាទាំង២នេះចូលស្ថាពររួចហើយ។

សំណូមពរសុំស្រូបទោសបញ្ចូលគ្នា។

+2y6 (accident) Rape -5y

**I-សំណុំរឿងព្រហ្មទណ្ឌលេខ៥២១/០១-៩-២០០៩របស់សាលាឧទ្ធរណ៍ៈ**

*បានឃើញ*សាលក្រមព្រហ្មទណ្ឌលេខ២២ប/២៩-៧-២០០៩របស់សាលាដំបូងខេត្តកណ្តាល សំរេចសេចក្តីដូចតទៅៈ

១-ផ្តន្ទាទោសលើឈ្មោះ[redacted]សុខលីន ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ី កម្មកររោងចក្រ ទីកន្លែងកំណើត និង ទីលំនៅសព្វ[redacted] ស្រុកអង្គស្នូល ខេត្តកណ្តាល ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ[redacted](រ) ប្រពន្ធឈ្មោះ[redacted]មានកូន១នាក់ ទោសពីមុនគ្មាន កំណត់ចំនួន០២ឆ្នាំ(ពីរឆ្នាំ) គឺទោសគុកចំនួន០១ឆ្នាំ(មួយឆ្នាំ)គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី២៥-១០-២០០៨ ទោសព្យួរចំនួន០១ឆ្នាំ(មួយឆ្នាំ) ដោយគិតរយៈពេលសាកល្បងចំនួន០៥ឆ្នាំ(ប្រាំឆ្នាំ) គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ពីបទបើកបរបង្កឲ្យស្លាប់អ្នកដទៃដោយចេតនាប្រព្រឹត្តនៅភូមិព្រៃរកា ឃុំធក់ឈើនាង ស្រុកអង្គស្នូល ខេត្តកណ្តាល កាលពីថ្ងៃទី២៥-១០-២០០៨បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៨២ នៃច្បាប់ស្តីពីចរាចរផ្លូវគោក។

២-សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ស៊ីន កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] សាខន ទុកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៩-៧-២០០៩របស់ព្រះរាជអាជ្ញារង [redacted] មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២២ប/២៩-៧-២០០៩របស់សាលាដំបូងខេត្តកណ្តាល គ្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**បានឃើញ**សាលដីកាព្រហ្មទណ្ឌលេខ០៦ក្រ៥.ប/១៧-០២-២០១១របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីដូចតទៅៈ

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៩-៧-២០០៩របស់ព្រះរាជអាជ្ញារង[redacted] ទុកជាត្រឹមត្រូវតាមច្បាប់។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ២២ប/២៩-៧-២០០៩របស់សាលាដំបូងខេត្ត

កណ្តាលទុកជាបានការ លើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោះ[redacted]សុខលីន ត្រូវកែប្រែពី០២ឆ្នាំ(ពីរឆ្នាំ)ទៅ០២ឆ្នាំ៦ខែ(អនុវត្តទោសក្នុងពន្ធនាគារ)វិញ។ក្រៅពីនេះ រក្សាទុកជាបានការដដែល។

៣-បន្តឃុំខ្លួនជនជាប់ចោទ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

II-សំណុំរឿងព្រហ្មទណ្ឌលេខ៩០១/០១-១០-២០១០របស់សាលាឧទ្ធរណ៍៖

*បានឃើញ*សាលក្រមព្រហ្មទណ្ឌលេខ៣៣«ស»/០២-៤-២០១០របស់សាលាដំបូងខេត្តកណ្តាល សំរេចសេចក្តីដូចតទៅ៖

១-ផ្តន្ទាទោសលើឈ្មោះ[redacted] សុខលីន ហៅ ហ៊ីង ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១៥ឆ្នាំ(ដប់ប្រាំឆ្នាំ) ពីបទរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី១២-៥-២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥ នៃច្បាប់ស្តីស្តានទំងន់ទោសនៃបទឧក្រិដ្ឋ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ[redacted] សុខលីន សងសំណងជំងឺចិត្តចំនួន១០.០០០.០០០(ដប់លាន)រៀល ទៅឲ្យជនរងគ្រោះឈ្មោះ[redacted]ស្រីពៅ ដែលមានឈ្មោះ[redacted]ច្រឹប ជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលសាលក្រមចូលជាស្ថាពរ។

៣-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី១៩-៣-២០១០ និង ប្រកាសជាសាធារណៈនៅថ្ងៃទី០២-៤-២០១០ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] សុខលីន និង ចំពោះមុខជនរងគ្រោះឈ្មោះ[redacted] ស្រីពៅ ហៅ [redacted]អ៊ាយ និង ឈ្មោះ[redacted] ច្រឹប ជាដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៧-៤-២០១០របស់ឈ្មោះសេង សុខលីន មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៣៣ស/០២-៤-២០១០របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**បានឃើញ**សាលដីកាព្រហ្មទណ្ឌលេខ៩៣ក្រIII«ឃ»/២៥-១០-២០១១ របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៧-៤-២០១០ ឈ្មោះ[redacted] សុខលីន ទុកជាត្រឹមត្រូវតាមច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ៣៣«ស»/០២-៤-២០១០របស់សាលាដំបូងខេត្តកណ្តាលទុកជាបានការ លើកលែងចំណុចទី១ត្រូវកែប្រែជាថ្មី៖

-ផ្តន្ទាទោសឈ្មោះ[redacted] សុខលីន ហៅ ហ៊ីង ភេទប្រុស អាយុ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់០៥ឆ្នាំ(ប្រាំឆ្នាំ)ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី១២-៥-២០០២ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស

តាមមាត្រា១០ , ២៣៩ , ៩៣ និង មាត្រា៩៨នៃក្រមព្រហ្មទណ្ឌ។

ចំណុចផ្សេងពីនេះនៃសាលក្រមរក្សាទុកជាបានការដដែល។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៤-សាលដីកានេះជំនុំជំរះនៅថ្ងៃទី១៣-១០-២០១១ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៥-១០-២០១១ ចំពោះមេធាវីការពារសិទ្ធិជនជាប់ចោទ និង ជនជាប់ចោទកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះ។

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍.

បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការ.

## **នាពេលសវនាការ**

ចៅក្រមអានរបាយការណ៍របស់សាលាឧទ្ធរណ៍.

*ជនជាប់ចោទឈ្មោ*[redacted] *សុខលីន ឆ្លើយថា៖*ខ្លួនមានឈ្មោះហ៊ុង ជាតិខ្មែរ មុខរបរកម្មកររោងចក្រ កើតនៅ និង ទីលំនៅសព្វថ្ងៃភូមិថ្ម[redacted] ស្អាល ខេត្តកណ្តាល ឪពុកឈ្មោ[redacted](រ)ម្តាយឈ្មោះ[redacted]ប្រពន្ធឈ្មោះ[redacted] មានកូន១នាក់ ។ទោសពីមុន គ្មាន។ចាប់ខ្លួនថ្ងៃទី២៥-០១-២០០៨។ខ្លួនជាប់ក្នុងពន្ធនាគារបានចំនួន០៥ឆ្នាំ២ខែហើយ។ទោសសរុប៧ឆ្នាំ៦ខែ។ខ្លួនសុំស្រាលទោស និង សុំបន្ថយទោសខ្លួនឲ្យបានទាប នៅក្នុងពន្ធនាគារខ្លួនបានកែប្រែខ្លួនបានល្អ ឪពុកម្តាយខ្លួនគាត់ចាស់ៗណាស់ហើយ។សុំស្រាលទោសត្រឹមចំនួន៥ឆ្នាំ។

*តំណាងមហាអយ្យការសន្និដ្ឋានថា៖*ការសុំស្រាលទោសរបស់ឈ្មោ[redacted]សុខលីន នេះ យល់ឃើញថា៖

សំណុំរឿងទី១ ជាប់ចោទពីបទ បើកបរបង្កឲ្យស្លាប់អ្នកដទៃដោយចេតនា ត្រូវផ្តន្ទាទោសរយៈពេល០២ឆ្នាំ៦ខែ សំណុំរឿងទី២ ជាប់ចោទពីបទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសរយៈពេល៥ឆ្នាំនោះ ជនជាប់ចោទបានជាប់ក្នុងពន្ធនាគារសមល្មមហើយ តំណាងមហាអយ្យការមិនយល់ទាស់នឹងការសុំស្រាលទោសរបស់ជនជាប់ចោទទេ សុំពិចារណាតាមមាត្រា៥០១ និង មាត្រា១៣៨នៃក្រមព្រហ្មទណ្ឌ។

*មេធា*[redacted] *ម៉ាច សន្និដ្ឋានថា៖*ខ្លួនជាមេធាវីការពារឲ្យឈ្មោះ[redacted] សុខលីន។កូនក្តីខ្លួនបានសុំស្រាលទោស។កូនក្តីខ្លួនបានជាប់ក្នុងពន្ធនាគារចំនួន០៥ឆ្នាំ២ខែហើយ គាត់បានកែប្រែអត្តចរិកបានល្អ។សំណូមពរសុំស្រាលទោស និង ផ្តល់ស្ថានសំរាលផង។

## **សភាព្រហ្មទណ្ឌ យល់ឃើញថា**

១-បណ្តឹងសុំស្រាលទោសចុះថ្ងៃទី១៥-៧-២០១៣របស់ទណ្ឌិតឈ្មោ[redacted]សុខលីន ធ្វើឡើងត្រឹមត្រូវតាមច្បាប់ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍អាចលើកយកមកជំនុំជំរះបាន តាមមាត្រា៥០១នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-ទណ្ឌិតឈ្មោះ[redacted]សុខលីន ភេទប្រុស អាយុ១៧ឆ្នាំ ត្រូវបានផ្តន្ទាទោសពន្ធនា

គារ៖

-ចំនួន០៥ឆ្នាំ(ប្រាំឆ្នាំ)តាមសាលដីកាព្រហ្មទណ្ឌលេខ៩៣ក្រIIIយ/២៥-១០-២០១១ របស់សាលាឧទ្ធរណ៍។

-ចំនួន០២ឆ្នាំ៦ខែ(ពីរឆ្នាំប្រាំមួយខែ)តាមសាលដីកាព្រហ្មទណ្ឌលេខ០៦ក្រ៥.ប/១៧-០២-២០១១របស់សាលាឧទ្ធរណ៍។

៣-ឈ្មោះសេង [redacted] លីន បានប្រព្រឹត្តបទល្មើស២លើក ការទោសប្រកាន់ផ្សេងពីគ្នា ដូចនេះសភាព្រហ្មទណ្ឌគប្បីពិចារណាពីការសុំស្របទណ្ឌកម្ម តាមមាត្រា១៣៨នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសុំស្របទោសចុះថ្ងៃទី១៥-៧-២០១៣របស់ទណ្ឌិតឈ្មោះ [redacted] សុខលីន ទុកជាត្រឹមត្រូវតាមច្បាប់។

២-ស្របបញ្ចូលសាលដីកាព្រហ្មទណ្ឌលេខ៩៣ក្រIIIយ/២៥-១០-២០១១របស់សាលាឧទ្ធរណ៍ និង សាលដីកាព្រហ្មទណ្ឌលេខ០៦ក្រ៥.ប/១៧-០២-២០១១របស់សាលាឧទ្ធរណ៍ លើទណ្ឌិតឈ្មោះ [redacted] សុខលីន ភេទប្រុស អាយុ១៧ឆ្នាំ ពីទោសសរុបចំនួន ០៧ឆ្នាំ៦ខែ មកជាទោសត្រូវអនុវត្តគឺចំនួន០៦ឆ្នាំ(ប្រាំមួយឆ្នាំ)។

៣-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី០៨-០១-២០១៤ ចំពោះមុខមេធាវី និង ទណ្ឌិត ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ដំណែងជួយសហការអនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមត្រូវតាមច្បាប់.**

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

ហត្ថលេខា [redacted] ហត្ថលេខា [redacted] . [redacted]. ហត្ថលេខា [redacted]

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍,ថ្ងៃទី ២០ ខែ ០១ ឆ្នាំ២០១៤

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍**

**ក្រឡាបញ្ជី**

[redacted]

[redacted]